សុន្ទរកថារបស់ **លោក ហ៊ីរ៉ូភ្លីជី យ៉ូស៊ីហ៊ីរ៉ូ**
ឧបទូត/អនុប្រធានបេសកកម្មទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីសម្ពោធប្រព័ន្ធចម្រោះទឹកស្អាតក្នុងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ
២៥ កុម្ភៈ ២០១៤

**សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ!**
**សូមគោរព ឯកឧត្តម ជូ យិនស៊ីម រដ្ឋលេខាធិការក្រសួងសុខាភិបាល!**
**សូមគោរព ឯកឧត្តម គោ ស៊ុំសារឿត អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ!**
**សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសទាំងអស់!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីចូលរួមក្នុងពិធីសម្ពោធប្រព័ន្ធចម្រោះទឹកស្អាតនៅក្នុងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យនៅថ្ងៃនេះជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមជូយិនស៊ីមរដ្ឋលេខាធិការក្រសួងសុខាភិបាល។

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក-អ្នកទាំងអស់ដែលបានចូលរួមក្នុងការអនុវត្តគម្រោងនេះ និងជាពិសេស អង្គការសម្ព័ន្ធសុខភាពកុមារនិងសុខភាពបន្តពូជ (RACHA) ដែលបានផ្តួចផ្តើមគំនិតសហការជាមួយមន្ទីរសុខាភិបាលខេត្ត។

គម្រោងដែលចំណាយថវិកាសរុបប្រមាណដប់ម៉ឺនដុល្លានេះ មានគោលដៅជួយកែលម្អគុណភាពនៃការរស់នៅរបស់ប្រជាជននៅក្នុងស្រុកថ្មពួកតាមរយៈការផ្គត់ផ្គង់ទឹកស្អាតសម្រាប់ពិសារ។ ទឹក ស្អាតគឺជាតម្រូវការចាំបាច់របស់មនុស្សជាតិ ហើយ ការទទួលបានទឹកស្អាតអាចផ្តល់នូវលទ្ធផលជាវិជ្ជមានជាច្រើនជាពិសេសគឺជួយដល់ការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់ប្រជាជន។ ទស្សនៈវិស័យមួយដែលប្រទេសជប៉ុនតែងតែលើកស្ទួយយ៉ាងសកម្មក្នុងអង្គការសហប្រជាជាតិ និងស្ថាប័នអន្តរជាតិដទៃទៀតនោះ គឺ ការធានាឲ្យមានការទទួលបានទឹកស្អាតជាអចិន្ត្រៃយ៍គឺជាចំណែកមួយដ៏សំខាន់សម្រាប់ការធានានូវសន្តិសុខមនុស្សជាតិ ដោយផ្តោតសំខាន់ទៅលើសន្តិសុខជាបុគ្គលនៃប្រជាជនងាយរងគ្រោះ។

ខ្ញុំបានដឹងថាប្រជាជននៅក្នុងស្រុកថ្មពួកបានប្រឈមនឹងការលំបាកជាច្រើនដោយសារកង្វះទឹកនៅរដូវប្រាំង ហើយការផ្គត់ផ្គង់ទឹកស្អាតមិនគ្រប់គ្រាន់នេះបានធ្វើឲ្យប្រជាជនមូលដ្ឋានប្រឈមយ៉ាងខ្ពស់ទៅនឹងជំងឺដែលទាក់ទងនឹងកង្វះទឹកស្អាត ពិសេសចំពោះកុមារអាយុក្រោម៥ឆ្នាំ។ ខ្ញុំ សង្ឃឹមថា ប្រព័ន្ធចម្រោះទឹកស្អាតថ្មីនេះនឹងរួមចំណែកធ្វើឲ្យប្រជាជនអាចទទួលបានទឹកស្អាតក្នុងតម្លៃដែលអាចទទួលយកបាន ក៏ដូចជាកែលម្អស្ថានភាពសុខភាពរបស់ប្រជាជនផងដែរ។

រដ្ឋាភិបាលជប៉ុនចាត់ទុកការកែលម្អប្រព័ន្ធផ្គត់ផ្គង់ទឹកនិងសេវាសុខាភិបាលគឺជាវិស័យអាទិភាពដែលអាចជួយកម្ពុជាឲ្យសម្រេចគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម។ ដោយមូលហេតុនេះ រដ្ឋាភិបាលជប៉ុនបាន និងកំពុងផ្តល់ការគាំទ្រដល់គម្រោងទឹកស្អាតជាច្រើនទាំងនៅទីក្រុង និងតំបន់ជនបទ។

ការពង្រីកតំបន់ចែកចាយទឹកស្អាតក៏ជាវិស័យអាទិភាពមួយដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជាដូចដែលបានឆ្លុះបញ្ចាំងក្នុងយុទ្ធសាស្ត្រចតុកោណដោយផ្តោតសំខាន់ទៅលើការបង្កើនការទទួលបានទឹកស្អាតតាមរយៈការពង្រីកការផ្គត់ផ្គង់ទឹកស្អាតនៅតាមតំបន់ជនបទ និងទីប្រជុំជននានា ដែលនឹងធ្វើឲ្យមានការលើកស្ទួយសុខភាពប្រជាជនផងដែរ។ គម្រោងរបស់ប្រទេសជប៉ុនលើកនេះមានគោលដៅគាំទ្រដល់កម្ពុជាក្នុងវិស័យនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាប្រព័ន្ធចម្រោះទឹកស្អាតដែលជានិមិត្តរូបនៃមិត្តភាពដ៏កក់ក្តៅពីប្រទេសជប៉ុនក៏ដូចជាប្រជាជនជប៉ុននេះនឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវដោយប្រជាជនមូលដ្ឋាន ព្រមទាំងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ហើយកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!